# ជំពូកទី ៨

## ឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និង
## ព័ត៌មានផ្សេងទៀត ស្ដីពីការនាំចេញនិងនាំចូល

**មាត្រា ៥១.-**

បុគ្គលដែលចូលរួម ឬ ពាក់ព័ន្ធនឹងការនាំចេញ និងនាំចូល ត្រូវតែរក្សាឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀត រាប់បញ្ចូលទាំងព័ត៌មានជាសណ្ឋានអេឡិចត្រូនិកដែលត្រឹមត្រូវ និងគ្រប់គ្រាន់ ដែលពាក់ព័ន្ធនឹងការនាំចេញ ឬ នាំចូលនោះ ។

ត្រូវរាប់បញ្ចូលក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ នូវអ្នកនាំចូល អ្នកនាំចេញ ជើងសាគយ ប្រតិបត្តិករកន្លែងសន្និធិគយបណ្ដោះអាសន្ន និង ភណ្ឌាគារគយមានដែនកំណត់ ប្រតិបត្តិករដឹកជញ្ជូន និងបណ្ដាភាគីពាក់ព័ន្ធផ្សេងទៀត ។

ឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្ដាព័ត៌មានផ្សេងទៀត ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវរក្សាទុករយៈពេលដប់ (១០) ឆ្នាំ នៅទីកន្លែងធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥២.-**

តាមសំណើរបស់រដ្ឋបាលគយ បុគ្គលដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១ នៃច្បាប់នេះ មានកាតព្វកិច្ចផ្ដល់បង្ហាញនូវឯកសារ បញ្ជី គណនេយ្យ កំណត់ត្រា និងបណ្ដាព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការនាំចេញ និងនាំចូល សម្រាប់ការពិនិត្យផ្ទៀងផ្ទាត់របស់គយ ។

ប្រសិនបើបុគ្គលដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះអវត្តមាន អ្នកតំណាងរបស់បុគ្គលនោះ មានកាតព្វកិច្ចក្នុងការផ្ដល់ឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្ដាព័ត៌មានផ្សេងទៀត ។

ក្នុងករណីដែលមន្ត្រីគយតម្រូវ បុគ្គលដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះត្រូវ :

ក-ផ្ដល់ឯកសារតាមតម្រូវការរបស់មន្ត្រីគយ ។

ខ- ឆ្លើយរាល់សំណួរដែលត្រូវបានសួរដោយមន្ត្រីគយ ពាក់ព័ន្ធនឹងកិច្ចការទាំងឡាយដែលកើតឡើងក្រោមបញ្ញត្តិនៃច្បាប់នេះ ។

គ- បើកឱ្យដំណើរការនូវរាល់ឧបករណ៍ដើម្បីផ្តល់បង្ហាញនូវព័ត៌មានចាំបាច់នានាដល់មន្ត្រីគយតាមសំណើ ប្រសិនបើព័ត៌មានដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះត្រូវបានរក្សាទុកដោយមធ្យោបាយអេឡិចត្រូនិក ឬ ឧបករណ៍ផ្សេងទៀត ។

**មាត្រា ៥៣.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់តម្រូវការដោយឡែកនានាពាក់ព័ន្ធនឹងឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀតក្រោមបញ្ញត្តិមាត្រា ៥១ នៃច្បាប់នេះ ។

## ជំពូកទី ៩

## ទំនិញគ្មានការទាមទារ

**មាត្រា ៥៤.-**

ទំនិញគ្មានការទាមទារគឺជា :

ក- ទំនិញរក្សាទុកក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ឬ នៅក្នុងភណ្ឌាគារគយមានដែនកំណត់ ដែលហួសរយៈពេលកំណត់ក្រោមបញ្ញត្តិនៃច្បាប់នេះ ។

ខ- ទំនិញផ្ញើតាមប្រៃសណីយ៍ដែលគម្យជនបដិសេធមិនទទួលយក ឬ គម្យជនពុំត្រូវបានរកឃើញនិងមិនអាចបញ្ជូនទំនិញត្រឡប់ទៅអ្នកផ្ញើវិញបាន ។

គ- ទំនិញ និងមធ្យោបាយដឹកជញ្ជូនពុំជាប់អាយ័ត ដែលស្ថិតនៅក្នុងកន្លែងបញ្ចេញទំនិញពីគយ ហើយម្ចាស់បានបោះបង់ចោលជាលាយលក្ខណ៍អក្សរ ។

ប្រសិនបើម្ចាស់ទំនិញត្រូវបានស្គាល់ រដ្ឋបាលគយត្រូវផ្ញើដំណឹងជាបន្ទាន់ដល់ម្ចាស់ទំនិញគ្មានការទាមទារថា ទំនិញទាំងនោះនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈស្របតាមបញ្ញត្តិមាត្រា ៥៥ នៃច្បាប់នេះ កាលណាពុំមានការទាមទារក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ ។

ក្នុងករណីពុំអាចរកម្ចាស់ឃើញ ប្រវេសន៍សាធារណៈត្រូវធ្វើតាមពេល និងរបៀប





33/45